# II ឯកសារគណៈរដ្ឋមន្ត្រី

## ១—អនុក្រឹត្យ

ភ្នំពេញ,ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៣៣ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ**

**និងអនុវត្តនយោបាយកិច្ចការព្រៃឈើ**

* *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យ–ច្បាប់ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា–ប្រមាញ់និងនេសាទ

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិមួយ ដែលមានឈ្មោះថា « គណៈកម្មាធិការជាតិរៀបចំនិងអនុវត្តនយោបាយកិច្ចការព្រៃឈើ » ។

**មាត្រា ២ :** គណៈកម្មាធិការជាតិរៀបចំនិងអនុវត្តនយោបាយកិច្ចការព្រៃឈើមាន សមាសភាពដូចខាងក្រោម ÷

១_សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី ១ សហប្រធាន

២_សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ សហប្រធាន

៣_ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហអនុប្រធាន

៤_រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហអនុប្រធាន

៥_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៧_តំណាងក្រសួងការពារជាតិ សមាជិក

៨_តំណាងក្រសួងមហាផ្ទៃ សមាជិក

៩_តំណាងក្រសួងផែនការ សមាជិក

១០_តំណាងក្រសួងពាណិជ្ជកម្ម សមាជិក

១១_តំណាងក្រសួងបរិស្ថាន សមាជិក

១២_លោកប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ លេខាធិការប្រតិបត្តិ

**មាត្រា ៣ :** គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានលេខាធិការដ្ឋានមួយជាជំនួយការ ដឹកនាំដោយលេខាធិការប្រតិបត្តិនៃ គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ស្ថិតនៅក្រោមអាណាព្យាបាលក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។ សមាជិកនៃលេខាធិការដ្ឋានត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ តាមសំណើរបស់លេខាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ។

**មាត្រា ៤ :** គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានសិទ្ធិប្រើប្រាស់ត្រារបស់រាជរដ្ឋាភិបាល ។

- លេខាធិការដ្ឋាន នៃ គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

**មាត្រា ៥ :** គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ដំណើរការក្រោមការឧបត្ថម្ភរបស់ថវិកាជាតិ និង ជំនួយរបស់សហគមន៍អន្តរជាតិ ។

**មាត្រា ៦ :** គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ត្រូវទទួលបន្ទុកកំណត់ទស្សនៈទានតាមដាន និង វាយតំលៃលើនយោបាយព្រៃឈើ នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងក្របខ័ណ្ឌនេះគណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ មានភារកិច្ចសំខាន់ ៗ គឺ ÷

- សំរបសំរួលកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាល និង ជំនួយអន្តរជាតិលើបញ្ហានយោបាយព្រៃ ឈើ ។
- ជ្រើសរើសនិងគ្រប់គ្រងជំនួយបច្ចេកទេសពីក្រៅ ។
- សំរបសំរួលកិច្ចប្រឹក្សារវាងបណ្តាផ្នែកពាក់ព័ន្ធទាំងអស់ក្នុងវិស័យព្រៃឈើ ។
- រៀបចំកម្មវិធីវិនិយោគក្នុងវិស័យព្រៃឈើ ។
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើជូនរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ ។ ក្រៅពីនេះ គណៈកម្មាធិការជាតិរៀបចំ និង អនុវត្តនយោបាយកិច្ចការព្រៃឈើ ត្រូវទទួលបន្ទុកធ្វើសំណើគ្រប់ករណី ឬ គ្រប់គំរោងផែនការ សកម្មភាពលើនយោបាយព្រៃឈើ នៃ ប្រទេសជាតិ ។

**មាត្រា ៧ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង លោកប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *